GOODWIN | PROCTER

David B. Pitofsky
212.813.8972
dpitofsky@
goodwinprocter.com

Goodwin Procter LLP
Counselors at Law
The New York Times Building
620 Eight Avenue
New York, NY 10018
T: 212.813.8800
F: 212.355.3333

ថ្ងៃទី 3 ខែមករា ឆ្នាំ2011

<u>តាមរយៈអ៊ីម៉ែល</u> (barbier@laed.uscourts.gov)

The Honoral Carl J. Barbier
United States District Judge
Eastern District of Louisiana
500 Poydras, Room C256
New Orleans, Louisiana 70130

យោងលើ: *ទាក់ទងនឹងការធ្លាយប្រេង ដោយសារការខួងយកប្រេង "តំបន់ទឹកជ្រៅ (Deepwater Horizon)"* ឆ្នេរជាប់ឈូងសមុទ្រមិចស៊ីកូ ថ្ងៃទី20 ខែមេសា ឆ្នាំ 2010, MDL. លេខ 2179 (E.D.La., Barbier, J.)

គោរពជូនលោកចៅក្រម Barbier៖

ខ្ញុំតំណាងឲ្យស្ថាបនសម្របសម្រួលពាក្យបណ្តឹងសម្រាប់តំបន់ឆ្នេរជាប់ឈូងសមុទ្រ ("GCCF")។ ខ្ញុំសរសេរសំបុត្រដោយការគោព ដើម្បីជូនដំណឹងដល់តុលាការ ទាក់ទងនឹងជំហ៊ានដែលស្ថាបន GCCF កំពុងតែអនុវត្តដើម្បីឆ្លើយតបនឹងតម្រូវការដែលត្រូវបានកំណត់ឲ្យកាត់ប្រាក់តម្កល់ នៅក្នុងសាលក្រមនិងមូលហេតុ ដែលបានចុះនៅក្នុងបណ្តឹងវិវាទ ក្នុងឯកសារយោងខាងលើ នៅថ្ងៃទី28 ខែធ្នូ ឆ្នាំ2011 ("សេចក្តីបង្គាប់") ដោយសារថាស្ថាបន GCCF បានយល់អំពីតម្រូវការទាំងនេះ។

បន្ទាប់ពីបានទទួលសាលក្រមពីតុលាការ ស្ថាបន GCCF បានចាប់ផ្តើមចាត់វិធានការណ៍ភ្លាមៗ ដើម្បីធានាអំពីការអនុលោមតាមតម្រូវការនៃការកាត់ប្រាក់តម្កល់។ មានប្រសិទ្ធភាពចាប់ពីថ្ងៃទី30 ខែធ្នូ ឆ្នាំ2011 ស្ថាបន GCCF បានផ្អាកជាបណ្តោះអាសន្ននូវរាល់ការបង់ប្រាក់ទាំងអស់ដល់អ្នកប្តឹងទាមទារ និង ការចេញនូវលិខិតសេចក្តីកំណត់ពីការបង់ប្រាក់ណាមួយ។ ទាំងនេះគឺជាការសំខាន់ណាស់ ពីព្រោះស្ថាបន GCCF ត្រូវចាត់វិធានការណ៍ផ្នែករដ្ឋបាលជាច្រើន ដើម្បីអនុវត្តតាមតម្រូវការនៃសាលក្រម ដើម្បីចាប់ផ្តើមកាត់

ចំនួនទឹកប្រាក់ពីប្រាក់សំណង និង ដោយសារស្ថាបន GCCF កំពុងស្វែងរកការបញ្ជាក់បកស្រាយនៃសេចក្តីបង្គាប់ជាមួយតុលាការ មុនពេលចាប់ផ្តើមដំណើការអនុវត្តតាមតម្រូវការឲ្យកាត់ប្រាក់។

LIBNY/5172583.1

ស្ថាបន GCCF បច្ចុប្បន្ននេះកំពុងតែធ្វើបច្ចុប្បន្នភាពគេហទំព័ររបស់ខ្លួន ដើម្បីជូនដំណឹង ពីការផ្អាកបណ្ដោះអាសន្ននេះ ហើយនឹងដាក់ប្រកាសសាលក្រមនៅលើវេបសាយផងដែរ ជាមួយនឹងសេចក្ដីជូនដំណឹងដែលពន្យល់ពីមូលហេតុ ដំណើរការបន្តទៅមុខ ហើយទឹកប្រាក់ 6 ភាគរយ ដែលរំពឹងថានឹងត្រូវសងដោយស្ថាបន GCCF នឹងត្រូវកាត់ពីប្រាក់សំណងរបស់អ្នកប្ដឹងទាមទារ។

ក្នុងការអនុលោមតាមសាលក្រមរបស់តុលាការ ស្ថាបន GCCF មានបំណងធ្វើការផ្លាស់ប្ដូរ ដូចខាងក្រោម ចំពោះដំណើរការបង់ប្រាក់៖

- ស្ថាបន GCCF នឹងកាត់ប្រាក់តម្កល់ 6 ភាគរយ ពីប្រាក់សំណងដែលរំពឹងទុកទាំងអស់ ដែលផ្ដល់ជូនអ្នកប្ដឹងទាមទារ បន្ទាប់ពីពេលចាប់ផ្ដើមដំណើរការឡើងវិញ។ ចំនួនទឹកប្រាក់នេះ នឹងត្រូវដាក់បញ្ចូលក្នុងគណនីបញ្ញើរទុកក្នុងដៃតតីយជន (escrow account) ដែលគ្រប់គ្រងដោយតុលាការ។

- ចំនួនទឹកប្រាក់តម្កល់ 6 ភាគរយ ដែលត្រូវបានកាត់ នឹងត្រូវអនុវត្តចំពោះប្រាក់សំណងទាំងអស់ ដែលនឹងត្រូវផ្ដល់ឲ្យដល់អ្នកប្ដឹងទាមទារគ្រប់ៗរូប ដែលមិនទាន់ត្រូវបានគេចេញលិខិត សេចក្ដីកំណត់ពីការបង់ប្រាក់នៅឡើយ នៅត្រឹមថ្ងៃទី29 ខែធ្នូ ឆ្នាំ2011នេះ។

- ស្ថាបន GCCF ជាធម្មតាបានកាត់ទុកនូវប្រាក់តម្កល់ ដោយអនុលោមតាមការសុំតវ៉ា តាមផ្លូវច្បាប់ស្ដីពីការអនុវត្តការសងបំណុល ឬ ដីកាតុលាការនៃបណ្ដឹងរឹបអូសទ្រព្យពីតតីយជន ជាពិសេសទាក់ទងនឹងកាតព្វកិច្ចនៃការបង់ប្រាក់ចិញ្ចឹមកូនតាមសាលក្រមរបស់តុលាការ។ ស្ថាបន GCCF នឹងធ្វើតាមការសុំតវ៉ាតាមផ្លូវច្បាប់នៃប្រាក់ប្រដាប់ក្ដី ឬ ប្រាក់នៃបណ្ដឹងរឹប អូសទ្រព្យពីតតីយជន មុនពេលអនុវត្តនៃការកាត់ប្រាក់ 6 ភាគរយ។

ស្ថាបន GCCF ស្នើសុំលិខិតបញ្ជាក់ដោយការគោរពពីតុលាការ ដើម្បីបញ្ជាក់ថាការបកស្រាយនេះ គឺវាដូចគ្នាជាមួយនឹងសាលក្រមរបស់តុលាការ ក៏ដូចជាការអធិប្បាយច្បាស់លាស់ពីកាតព្វកិច្ចណាមួយ ដែលស្ថាបន GCCF អាចមានទាក់ទងនឹងការអនុវត្តតាមសាលក្រមរបស់តុលាការ ដើម្បីដកប្រាក់មកវិញ ចំពោះប្រាក់សំណងដែលបានផ្ដល់ឲ្យដល់អ្នកប្ដឹងទាមទាររួចហើយ នៅថ្ងៃទី ឬក្រោយពីថ្ងៃទី7 ខែវិច្ឆិកាឆ្នាំ2011។

ដោយសេចក្ដីស្មោះត្រង់ពី
(ហត្ថលេខា)
David B. Pitofsky

LIBNY/5172583.1